ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៦
ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩
-សាលក្រមលេខ : **០១ "ខ"**
ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅបន្ទប់សវនាការលេខ ០២
បានដំណើរការនីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទ ១៣ ខែ ធ្នូ ឆ្នាំ ២០១៩ វេលា រសៀល
បានបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៩ វេលា រសៀល
កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០ ត្រូវនឹងថ្ងៃ សុក្រ ១រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ វេលា ព្រឹក ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមនៃសាលាដំបូង ខេត្តសៀមរាប ។

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូង ខេត្តសៀមរាប ។

ដើមចោទឈ្មោះ [redacted] **សុចិន្តា** ភេទស្រី អាយុ ៥២ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

អ្នកតំណាងដោយអាណត្តិ ៖ លោកមេធាវី [redacted]

ចុងចម្លើយឈ្មោះ [redacted] **ឡាយ** ភេទស្រី អាយុ ៨៦ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

អ្នកតំណាងដោយអាណត្តិ ៖ លោកមេធាវី [redacted] និងលោកមេធាវី [redacted]

### អង្គហេតុ និង ចំណុចវិវាទ :

**ក - សាលក្រមតាមទាមទារដោយដើមចោទ :**

ដើមចោទទាមទារឱ្យសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមសម្រេចដូចតទៅ :

១.បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] **សុចិន្តា** សងប្រាក់ដើមចំនួន ១៩.០៦៣,៥០$ (ដប់ប្រាំបួនពាន់ហុកសិបបីកដុល្លារអាមេរិកនិងហាសិបសេន) ទៅឲ្យចុងចម្លើយឈ្មោះ [redacted] **ឡាយ** ។

២.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ឡាយ** ប្រគល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-១៥០០ ដីស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មកឲ្យដើមចោទវិញ ។

៣.បង្គាប់ឲ្យចុងចម្លើយរ៉ាប់រង និងទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

៤.ប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី២ ខាងលើ ។

**ក.១ ចុងចម្លើយប្ដឹងតបទាមទារឱ្យសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមសម្រេចដូចតទៅ :**

**១**.ច្រានចោលគ្រប់ចំណុចការទាមទារនៃបណ្ដឹងលេខ ៣៦៦ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ របស់ដើមចោទ ។

**២**.បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] **សុចិន្តា** និងប្ដីឈ្មោះ [redacted] **សំអឿន** សងប្រាក់ចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ។

**៣**.បង្គាប់ឲ្យដើមចោទ បង់ការប្រាក់ក្នុង ០១ខែ ចំនួន ១,៥% តាមច្បាប់លើប្រាក់ដើមចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) គិតចាប់ពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៩ តទៅ រហូតដល់ថ្ងៃសងប្រាក់ដើមអស់ ។

**៤**.ឱ្យដើមចោទសងសំណងការខូចខាត និង ជម្ងឺចិត្តចំនួន ៥០.០០០.០០០៛ (ហាសិបលានរៀល) ។

**៥**.ប្រកាសអនុវត្តសាលក្រមនេះជាបណ្ដោះអាសន្ន ។

**៦**.ឲ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

**ខ-ការពន្យល់ត្រួសៗអំពីដំណើររឿងក្ដី :**

កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ ដើមចោទ បានខ្ចីប្រាក់ពីចុងចម្លើយចំនួន ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ការប្រាក់ចំនួន ៦០០$ (ប្រាំមួយរយដុល្លាអាមេរិក) ក្នុង០១ខែ ដោយដើមចោទបានដាក់ប្លង់ដី០១ប្លង់ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ: ១៧១០០២០៩-១៥០០ ស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ជាការធានាលើប្រាក់កម្ចីរបស់ដើមចោទចំនួន ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ។ ដើមចោទ បានបង់ការប្រាក់ឲ្យចុងចម្លើយជារៀងរាល់ខែ ចាប់ពីខែមេសារហូតដល់ខែ សីហា ឆ្នាំ ២០១៩ ។

នៅខែ មិថុនា ឆ្នាំ ២០១៩ ដើមចោទបានយកប្រាក់ចំនួន ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ទៅសងឲ្យចុងចម្លើយ ហើយសុំលោះយកប្លង់ដីមកវិញ តែចុងចម្លើយឈ្មោះ [redacted] **ឡាយ** មិនព្រមឲ្យប្លង់ដីដើមចោទវិញទេ ដោយនិយាយថា លុះត្រាតែកូនប្រុសរបស់ដើមចោទឈ្មោះ [redacted] សុភ័ក្រ និងប្រពន្ធឈ្មោះ [redacted] ស្រីពេជ្រ សងប្រាក់ឲ្យ (ចុងចម្លើយ) គ្រប់ ទើបចុងចម្លើយព្រមប្រគល់ប្លង់ដីមកឲ្យដើមចោទវិញ ។

**ខ-១-ការអះអាងរបស់សហដើមចោទ:**

អ្នកតំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍ថា ខ្លួនប្ដឹងសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម ៖

**១**.បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] **សុចិន្តា** សងប្រាក់ដើមចំនួន ១៩.០៦៣,៥០$ (ដប់ប្រាំបួនពាន់ហុកសិបបីកដុល្លាអាមេរិកនិងហាសិបសេន) ទៅឲ្យចុងចម្លើយឈ្មោះ [redacted] **ឡាយ** ដែលកូនក្ដីខ្លួន បានបង់ការប្រាក់លើសច្បាប់កំណត់ចំនួន ៩៣៦,៥០$ (ប្រាំបួនរយសាមសិបប្រាំមួយក្បៀសហាសិបដុល្លាអាមេរិក) ដោយហេតុថាកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ កូនក្ដីខ្លួនឈ្មោះ [redacted] **សុចិន្តា** ប្ដីឈ្មោះ

[redacted] **សំអឿន** បានទៅខ្ចីប្រាក់ពីចុងចម្លើយឈ្មោះ [redacted] **ឡាយ** ដែលត្រូវជាបងប្អូនជីដូនមួយនឹងគ្នា ហើយជាអ្នករកស៊ីចងការប្រាក់ និងវេរប្រាក់ (WING) ចំនួន **២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)** អត្រាការប្រាក់ ៣% ក្នុងមួយខែលើប្រាក់ដើម **២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)** ហើយបានដាក់តម្កល់ប្លង់ដីមួយប្លង់ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-១៥០០ ជាការធានា កូនក្តីខ្លួនបានបង់ការប្រាក់ជារៀងរាល់ខែគឺសម្រាប់ ខែមេសា និង ខែ ឧសភា ឆ្នាំ ២០១៩ បង់ការប្រាក់ចំនួន **១២០០$(មួយពាន់ពីររយដុល្លារអាមេរិក)** លើប្រាក់ដើម **២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)** បង់ផ្ទាល់ដៃ ។

នៅខែ មិថុនាឆ្នាំ ២០១៩ កូនក្តីខ្លួនបានសុំសងប្រាក់ដើមចំនួន ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ហើយសុំលោះយកប្លង់ដីមកវិញ ដោយកូនក្តីខ្លួនត្អូញត្អែរថា រត់ការប្រាក់មិនរួចទេ ចង់សុំយកប្លង់ដីទៅដាក់ខ្ចីពីខាងធនាគារវិញ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ឡាយ មិនយល់ព្រមប្រគល់ប្លង់ដីឲ្យកូនក្តីខ្លួនទេ តែបែរជាបញ្ចុះការប្រាក់ឲ្យកូនក្តីខ្លួន គឺពី **៣%** ក្នុងមួយខែមកត្រឹម **២%** ក្នុងមួយខែវិញ លើប្រាក់ដើម **២០.០០០$ (ពីម៉ឺនដុល្លារអាមេរិក)** ។ ពីខែ មិថុនា, កក្កដា និង សីហា ឆ្នាំ ២០១៩ កូនក្តីខ្លួនបានបង់ការប្រាក់ឲ្យចុងចម្លើយចំនួន **១២០០$ (មួយពាន់ពីររយដុល្លារអាមេរិក)** បង់តាមវីងវេរលុយ យីហោ (កូនខ្មែរ) ។

នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៩ កូនក្តីខ្លួនបានទៅជួបចុងចម្លើយឈ្មោះ [redacted] ឡាយ ម្តងទៀត ជាមួយសាក្សីឈ្មោះ [redacted] សួរ ក្រុមប្រឹក្សាឃុំ ដើម្បីសុំសងប្រាក់ដើមចំនួន ២០.០០០$(ពីរម៉ឺនដុល្លារអាមេរិក) ហើយសុំលោះប្លង់ដីយកមកវិញដើម្បីខ្ចីប្រាក់នៅធនាគារ ដោយអង្វរចុងចម្លើយថា ខ្លួនរត់ការប្រាក់មិនរួចទេ តែចុងចម្លើយឈ្មោះ [redacted] ឡាយ នៅតែមិនព្រមប្រគល់ប្លង់ដីឲ្យកូនក្តីខ្លួនទេ តែបែរជានិយាយថា លុះត្រាណាតែកូនក្តីខ្លួនសងប្រាក់ដើមចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ទើបចុងចម្លើយយល់ព្រមប្រគល់ប្លង់ដីឲ្យ ។ ហើយក៏មានការប្រកែកប្រណាំងគ្នាអំពីទឹកប្រាក់ ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ទៅ ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ទើបចុងចម្លើយប្រាប់ថាប្រាក់ចំនួន ៣៤.៨០០$ (បីម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) គឺជាប្រាក់ឈ្មោះ [redacted] សុភ័ក្រ ដែលត្រូវជាកូនរបស់ដើមចោទជំពាក់ កូនក្តីខ្លួនបានតវ៉ាថារឿងកូនខ្លួនខ្ចី ប្រាក់ពីចុងចម្លើយប៉ុន្មាន បានសងវិញអស់ប៉ុន្មាន នៅសល់ប៉ុន្មានខ្លួនមិនបានដឹងទេ ហើយខ្លួនមិនបានធានាលើបំណុលកូនខ្លួននោះទេ ។ក្នុងពេលនោះចុងចម្លើយក៏មិនទាន់បានបង្ហាញឯកសារលិខិតខ្ចីប្រាក់ចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ចុះខែ មីនា ឆ្នាំ ២០១៩ នេះនៅឡើយទេ ។

នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ដោយអស់លទ្ធភាពនឹងសម្របសម្រួលគ្នាបាន ទើបកូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តសៀមរាប ពេលនោះទើបកូនក្តីខ្លួនបានឃើញឯកសារលិខិតខ្ចីប្រាក់ថាកូនក្តីខ្លួន ជំពាក់ប្រាក់ចុងចម្លើយចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ពីចុងចម្លើយតាមរយៈបណ្តឹងតបរបស់ចុងចម្លើយចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៩ ។ ឯកសារលិខិតខ្ចីប្រាក់ដែលចុងចម្លើយបានបង្ហាញក្នុងបណ្តឹងតបនេះគឺជាលិខិតបន្លំ បំភាន់ ដែលចុងចម្លើយបាន

បង្កើតឡើងដោយខ្លួនឯងមិនមែនចេញពីសុឆន្ទៈ ពិតប្រាកដរបស់កូនក្តីខ្លួនទេ ឯកសារនេះគឺមានភាពវិការៈខ្លាំងណាស់ ប្រសិនបើយើងប្រៀបធៀបគ្នារវាងឯកសារលិខិតខ្ចីប្រាក់ទាំងពីរ គឺ ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) និង ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ទម្រង់សរសេរ គឺមានភាពវិការៈ ដោយវាយកុំព្យូទ័រ ទុកចន្លោះប្រហោងសម្រាប់បំពេញថែមបន្ថែម ។

២.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ឡាយ** ប្រគល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **១៧១០០២០៩-១៥០០** ដីស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មកឲ្យដើមចោទវិញ ដោយហេតុថាប្លង់ដីនេះ គឺ កូនក្តីខ្លួនដាក់តម្កល់ធានាលើបំណុលដែលកូនក្តីខ្លួនបានខ្ចីផ្ទាល់ពីចុងចម្លើយឈ្មោះ [redacted] **ឡាយ** ចំនួន **២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក)** ដូច្នេះនៅពេលកូនក្តីខ្លួនសុំសងប្រាក់ដើម **២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក)** ចុងចម្លើយត្រូវប្រគល់ប្លង់ដីមកឲ្យកូនក្តីខ្លួនវិញ ។

៣.បង្គាប់ឲ្យចុងចម្លើយរ៉ាប់រង និង ទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយហេតុថារឿងក្តីនេះជាកំហុសរបស់ចុងចម្លើយពុំយល់ព្រមប្រគល់ប្លង់ដីមកឲ្យកូនក្តីខ្លួនទើបបានជាមានការប្តឹងផ្តល់គ្នាតាមផ្លូវតុលាការ ។

៤.ប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី២ ដោយហេតុថាកូនក្តីខ្លួនត្រូវយកប្លង់ដីនេះមករក្សាទុកខ្លួនឯងវិញ ។

**ក-១-ការអះអាងរបស់សហចុងចម្លើយ**:

អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍តបវិញថាខ្លួនសុំធ្វើការច្រានចោលទាំងអស់រាល់ការទាមទាររបស់ដើមចោទ និងរាល់ការថ្លែងរបស់អ្នកតំណាងឲ្យដើមចោទហើយខ្លួនសុំទាមទារដូចមានអត្ថន័យនៅក្នុងបណ្តឹងតបរបស់កូនក្តីខ្លួនចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៩ ដដែលដោយហេតុថាកាលពីដើមឆ្នាំ ២០១៩ ដើមចោទឈ្មោះ [redacted] សុចិន្តា តែងតែប្រើកូនឈ្មោះ [redacted] សុភ័ក្រ មកខ្ចីចងការប្រាក់ពីកូនក្តីខ្លួន ដោយយល់ថាត្រូវជាញាតិនឹងគ្នា កូនក្តីខ្លួនតែងតែយោគយល់ជានិច្ច ។ ប្រាក់ដែលឈ្មោះ [redacted] សុភ័ក្រ ខ្ចីមានចំនួន ៣៤.៨០០$ (បីម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ។ កូនក្តីខ្លួន បានធ្វើការបញ្ជីបូកសរុបឲ្យសហដើមចោទរួចហើយ គឺសហដើមចោទទទួលរ៉ាប់រងសងជំនួសទាំងអស់ ។

កាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩ ឈ្មោះ [redacted] សុភ័ក្រ បានទូរស័ព្ទមកខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន **២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក)** ពេលនោះកូនក្តីខ្លួនបដិសេធ តែដើមចោទឈ្មោះ [redacted] សុចិន្តា បានមកអង្វរកូនក្តីខ្លួន ទើបកូនក្តីខ្លួនអាណិត ក៏យល់ព្រមឲ្យដើមចោទខ្ចីថែមទៀត ហើយដើមចោទជាអ្នកចេញមុខផ្ទាល់ ដោយឲ្យដើមចោទដាក់បញ្ចាំប្លង់ដី ។ ដើមចោទឈ្មោះ [redacted] សុចិន្តា និងកូនឈ្មោះ [redacted] សុភ័ក្រ នៅផ្ទះជាមួយគ្នារកស៊ីជាមួយគ្នា ។ ហេតុនេះហើយទើបនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៩ កូនក្តីខ្លួន បានប្រគល់ប្រាក់ឲ្យដើមចោទឈ្មោះ [redacted] សុចិន្តា ចំនួន **២០.០០០$(ពីរម៉ឺនដុល្លាអាមេរិក)** ឲ្យសុំបូកបញ្ចើសរុបចំនួន **៥៤.៨០០$(ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក)** ។ (បូករួមទាំងកូនឈ្មោះ



Scanned with CamScanner

[redacted] សុភ័ក្រ ខ្ចីផង) ព្រមទាំងឲ្យយកប្លង់ដីដាក់បញ្ចាំផង ដល់ពេលនេះសហដើមចោទបែរជាចង់មករលាស់យករួចខ្លួន ចង់សងតែប្រាក់ចំនួន ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ។ រីឯប្រាក់ចំនួន ៣៤.៨០០$ (បីម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ទៀតមិនព្រមសង ដោយចេតនាទុច្ចរិតបំពានសេចក្តីទុកចិត្ត និងស្រឡាញ់រាប់អានគ្នាក្នុងនាមជាញាតិទៅវិញ ។ ហេតុនេះ កូនក្តីខ្លួនសូមទាមទារប្រាក់ក្នុងបណ្តឹងតបចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៩ ដដែលគឺ

១. ច្រានចោលការទាមទាររបស់ ដើមចោទក្នុងបណ្តឹងចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ចោលជាអាសារបង់ ។

២. បង្គាប់ឲ្យសហដើមចោទសងប្រាក់ចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ឲ្យចុងចម្លើយ ។

៣. បង្គាប់ឲ្យសហដើមចោទបង់ការប្រាក់ ១,៥០% ក្នុង០១ខែលើប្រាក់ដើមចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) គិតចាប់ពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមអស់ ។

៤. បង្គាប់ឲ្យសហដើមចោទ សងជម្ងឺចិត្តសរុប ៥០.០០០.០០០រៀល (ហាសិបលានរៀល) ។

៥. ប្រកាសអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ន ។

៦. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហដើមចោទ ។

ដើមចោទបានថ្លែងថា ការថ្លែងរបស់លោកមេធាវីចុងចម្លើយ និងពាក្យបណ្តឹងតបរបស់ចុងចម្លើយគឺជាការមិនពិតទេខ្លួនសូមបដិសេធ ដោយហេតុថាកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ ខ្លួនបានទៅសុំខ្ចីប្រាក់ផ្ទាល់ពីចុងចម្លើយឈ្មោះ [redacted] ឡាយ ចំនួន ២០.០០០$(ពីរម៉ឺនដុល្លាអាមេរិក) ការប្រាក់ ០៣% ក្នុងមួយខែ ស្មើនឹង ៦០០$ (ប្រាំមួយរយដុល្លា) តាមលិខិតខ្ចីចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ តែលិខិតធ្វើនេះចុងចម្លើយរក្សាទុកខ្លួនគាត់ ។ គាត់ឲ្យខ្លួន ផ្តិតមេដៃឲ្យកូនខ្លួនឈ្មោះ [redacted] សុភ័ក្រ ផ្តិតមេដៃធានាលិខិតនោះ ឈ្មោះ [redacted] ឡាយ ធ្វើពីរច្បាប់គាត់បានបង្ហាញអត្ថន័យសន្លឹកខាងលើឲ្យខ្លួនបានឃើញច្បាស់ថាចំនួនប្រាក់ខ្ចីគឺ ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ការប្រាក់ ៦០០$ (ប្រាំមួយរយដុល្លាអាមេរិក) ក្នុងមួយខែ ខ្លួនក៏ផ្តិតមេដៃទាំងពីរសន្លឹកទៅ ដោយមិនបានមើលអត្ថន័យសន្លឹកខាងក្រោមក្រោមទេដោយទុកចិត្តថាបងប្អូនឯង ម្យ៉ាងទៀតពេលនោះចុងចម្លើយកាន់លិខិតជាប់ គាត់ជាអ្នកបើកកន្ទុយសន្លឹកឲ្យផ្តិតមេដៃ ហើយគាត់និយាយពីនេះពីនោះដើម្បីបន្លំ តែពេលនោះខ្លួនពុំចាប់អារម្មណ៍ទេ ។

នៅខែ មេសា ឆ្នាំ ២០១៩ ខ្លួនក៏បង់ការប្រាក់ ៦០០$ (ប្រាំមួយរយដុល្លាអាមេរិក) លើប្រាក់ដើម ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ទៅឲ្យឈ្មោះ [redacted] ឡាយ ផ្ទាល់ដៃ ។ នៅខែ ឧសភា ខ្លួនក៏បង់ការប្រាក់ចំនួន ៦០០$ (ប្រាំមួយរយដុល្លា) ឲ្យឈ្មោះ [redacted] ឡាយ ម្តងទៀត ហើយខ្លួនបានត្អូញត្អែរថាចង់រកដើម ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) មកសងលោះយកប្លង់ទៅខ្ចីធនាគារវិញការប្រាក់ថោកពេលនោះឈ្មោះ [redacted] ឡាយ មិនបាននិយាយអ្វីទេ តែគាត់បញ្ចុះការប្រាក់ឲ្យខ្លួនត្រឹម ៤០០$ (បួនរយ

ដុល្លារអាមេរិក) វិញ ។ នៅខែមិថុនា ខែកក្កដា និង ខែសីហា ឆ្នាំ ២០១៩ ខ្លួនក៏បង់ការប្រាក់ ១២០០$ (មួយពាន់ពីររយដុល្លារអាមេរិក) ឲ្យឈ្មោះ [redacted] ឡាយ តាមរយៈវីងវេរប្រាក់ឃីហោ (កូនខ្មែរ) ពេលនោះឈ្មោះ [redacted] ឡាយ មិនបាននិយាយអ្វីដែរ ។

នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៩ ខ្លួនក៏សម្រេចចិត្តទៅនិយាយជាមួយឈ្មោះ [redacted] ឡាយ ម្តងទៀតដើម្បីសុំសងប្រាក់ដើមចំនួន ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ជាមួយឈ្មោះ [redacted] សួរ ក្រុមប្រឹក្សាឃុំ ហើយសុំលោះយកប្លង់ដីទៅខ្ចីធនាគារវិញ ឈ្មោះ [redacted] ឡាយ មិនព្រម ពេលនោះទើបឈ្មោះ [redacted] ឡាយ បានប្រាប់ថាទាល់តែខ្លួនសងប្រាក់ដើមចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ដោយគាត់បូករួមថាកូនខ្លួនឈ្មោះ [redacted] សុភ័ក្រ និងប្រពន្ធវា បានខ្ចីចំនួន ៣៤.៨០០$ (បីម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ផងទើបឲ្យប្លង់ដីវិញ ។ តែគាត់មិនបានបង្ហាញលិខិតខ្ចីប្រាក់ ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ដែលគាត់បន្លំឲ្យខ្លួនបានឃើញនៅឡើយទេ ។ គាត់គ្រាន់តែប្រាប់ថាប្រាក់ចំនួន ៣៤.៨០០$ (បីម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ជាប្រាក់កូនខ្លួនឈ្មោះ [redacted] សុភ័ក្រ ខ្ចី ខ្លួនក៏តវ៉ាថារឿងអ្វីឲ្យខ្លួនសងជំនួសកូន កូនវាខ្ចីប៉ុន្មាន, សងប៉ុន្មាន, សល់ប៉ុន្មាន, ក៏ខ្លួនមិនបានដឹងផងនោះ ចុះបើរឿងដូច្នេះមែនហេតុអ្វីមិនប្រាប់ពីដំបូង ។ ហេតុនេះហើយទើបខ្លួនប្តឹងមកតុលាការ ហើយក៏បានឃើញលិខិតខ្ចីប្រាក់ចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ដែលឈ្មោះ [redacted] ឡាយ បានបន្លំឱ្យខ្លួនផ្តិតមេដៃ ។ ខ្លួនសុំឲ្យតុលាការអញ្ជើញចុងចម្លើយឈ្មោះ [redacted] ឡាយ ចូលមកតទល់នៅល្ងាចនេះតែចុងចម្លើយមិនហ៊ានមកតទល់ទេ ។ ខ្លួនសូមជម្រាបថាខ្លួនមិនបានដឹងថាកូនខ្លួនឈ្មោះ [redacted] សុភ័ក្រ និងប្រពន្ធរបស់វាខ្ចីប្រាក់ចុងចម្លើយឈ្មោះ [redacted] ឡាយ ប៉ុន្មានលើក ចំនួនប៉ុន្មាន សល់ប៉ុន្មាននោះទេ ហើយខ្លួនក៏មិនបានដឹងថាចុងចម្លើយឈ្មោះ [redacted] ឡាយ បានដាក់ផ្ទាប់លិខិតខ្ចីប្រាក់ បន្លំឲ្យខ្លួនផ្តិតមេដៃដែរ ព្រោះខ្លួនបង់ការប្រាក់ឲ្យចុងចម្លើយរាល់ខែ គឺខ្លួនបង់ការប្រាក់លើតែទឹកប្រាក់ដើមចំនួន ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក) តែប៉ុណ្ណោះ ហើយចុងចម្លើយក៏មិនដែលប្រកែកឬជំទាស់ដែរ ចុងចម្លើយទើបតែប្រើល្បិចក្រោយពេលខ្លួនប្តឹងមកតុលាការទេ ។ ប្រសិនបើខ្លួនបង់តែការប្រាក់ចំនួន ៤០០$ (បួនរយដុល្លារអាមេរិក) លើប្រាក់ដើមចំនួន ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ឱ្យគាត់របូត គាត់ក៏មិនបង្ហាញឯកសារដែល គាត់បន្លំចំនួន ៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក) នេះដែរ ។

សាក្សីឈ្មោះ [redacted] សុភ័ក្រ បានថ្លែងថារាល់ពេលដែលខ្លួននិងប្រពន្ធខ្លួនបានខ្ចីប្រាក់ពីអ៊ុំ [redacted] ឡាយ ខ្លួនមិនដែលបានប្រាប់ម្តាយឈ្មោះ [redacted] សុចិន្តា ថាខ្លួនបានខ្ចីប៉ុន្មានលើក ចំនួនប៉ន្មានដឹងនោះទេ ព្រោះខ្លួនខ្ចីមករកស៊ីផ្ទាល់ខ្លួនដោយឡែក មិនមែនរកស៊ីជាមួយម្តាយ ដូចលោកមេធាវីចុងចម្លើយនិយាយទេ ហើយខ្លួនក៏មិនដែលបានឲ្យម្តាយឪពុកខ្លួនវ៉ាប់រងធានាលើបំណុលរបស់ខ្លួនដែរ ជារឿងរាល់ខែ គឺខ្លួនឬប្រពន្ធជាអ្នកឡើងលុយឲ្យអ៊ុំ [redacted] ឡាយ ។ ខ្លួននិងប្រពន្ធខ្លួនបានខ្ចីប្រាក់អ៊ុំ [redacted] ឡាយ ចំនួន៤លើកសរុបចំនួន ២៨.០០០$ (ពីរម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ការប្រាក់ ៨០% ក្នុង០១ថ្ងៃ យកជាលុយរាប់ ខ្លួនបានឡើងលុយរាប់ឲ្យអ៊ុំ ឡាយ រាល់ថ្ងៃទូទាត់ទៅនៅជំពាក់ប្រាក់ដើមចំនួន ៩.០០០$

(ប្រាំបួនពាន់ដុល្លាអាមេរិក) ខ្លួនក៏បានបែកគ្នាជាមួយប្រពន្ធ ក៏អាក់ខានមិនបានឡើងលុយឲ្យអ៊ី ឡាយ ចាប់ពីខែ សីហា ឆ្នាំ២០១៩ រៀងរហូតមកដល់បច្ចុប្បន្ន ទើបអ៊ីឡាយបូកការប្រាក់ទៅជាប្រាក់ដើម ហើយសរសេរឯកសារបន្លំឲ្យម្តាយខ្លួនផ្តិតមេដៃទទួលស្គាល់ថាបានជំពាក់ប្រាក់គាត់ចំនួន ៥៩.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ។ ពេលអ៊ី [redacted] ឡាយ ឲ្យខ្លួនផ្តិតមេដៃធានានៅលើលិខិតខ្ចីប្រាក់ចំនួន ២០.០០០$(ពីរម៉ឺនដុល្លាអាមេរិក) របស់ម្តាយខ្លួនឈ្មោះ [redacted] សុចិន្តា ខ្លួនបានឃើញឯកសារសន្លឹកខាងក្រោមចន្លោះប្រហោងមិនទាន់បំពេញ ខ្លួនបានសួរអ៊ី [redacted] ឡាយ គាត់និយាយពីនេះពីនោះ គាត់ថាមិនអីទេ កុំបារម្ភ គាត់ថា ខាងក្រុមហ៊ុនគាត់គេឲ្យធ្វើអញ្ចឹង ដោយទុកចិត្តថាជាសាច់ញាតិ ខ្លួនក៏ផ្តិតមេដៃលើឯកសារចន្លោះប្រហោងមិនទាន់បំពេញនោះឲ្យគាត់ទៅ ឯកសារនោះមិនមានបំពេញទឹកប្រាក់ទេគឺនៅចន្លោះចោល ។

- អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយតបវិញថា ឈ្មោះ [redacted] សុភ័ក្រ ឈ្មោះ [redacted] សុចិន្តា និង [redacted] សំអឿន សុទ្ធសឹងតែជានីតិជន មានការយល់ដឹងច្បាស់លាស់មិនអាចមកឆ្លើយក្រឡាស់តាមចិត្តខ្លួននោះបានទេ អ្វីៗគឺផ្អែកលើភ័ស្តុតាង ភ័ស្តុតាងបានបញ្ជាក់ថាសហដើមចោទពិតជាបានផ្តិតមេដៃនៅលើលិខិតខ្ចីប្រាក់ពីកូនក្តីរបស់ខ្លួនចំនួន ៥៩.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) មិនអាចគេចវេះពីការទទួលខុសត្រូវបានទេ ។
- អ្នកតំណាងអោយអាណត្តិឲ្យដើមចោទ បានថ្លែងតបវិញថា ការផ្តិតមេដៃនៅលើលិខិតខ្ចីប្រាក់ចំនួន ៥៩.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) របស់ដើមចោទដែលចុងចម្លើយបានដាក់បន្លំនេះ គឺវាមិនមែនស្តែងចេញពីសុឆន្ទៈពិតប្រាកដរបស់ដើមចោទទេ គឺដើមចោទមិនបានដឹងថាចុងចម្លើយដាក់លិខិតផ្ទាប់បន្លំអោយដើមចោទផ្តិតមេដៃទេ ម្យ៉ាងទៀតគឺភ័ស្តុតាងនេះមានភាពវិការៈខ្លាំងណាស់ សូមតុលាការមេត្តាពិនិត្យមើលទម្រង់នៃលិខិតខ្ចីប្រាក់ទាំងពីរច្បាប់នេះ ព្រោះដំបូងនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ បានខ្ចីប្រាក់ពីចុងចម្លើយចំនួន ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ហេតុដូចម្តេចក៏មានលិខិតខ្ចីប្រាក់ចំនួន ៥៩.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) មួយផ្សេងទៀត ហើយចុះកាលបរិច្ឆេទថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ តែមួយដូចគ្នា ពីព្រោះថា បើមានការបូកបញ្ចូលទូទាត់ដូចចុងចម្លើយបានលើកឡើងនោះមែននោះ វាគួរតែមានលិខិតសរុបចំនួនទឹកប្រាក់ចុងក្រោយតែមួយច្បាប់ទេគឺ ៥៩.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) តែករណីនេះគឺមានលិខិតខ្ចីដល់ទៅពីរគឺ ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ក៏មាន ៥៩.៨០០$(ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) ក៏មាននេះជាភ័ស្តុតាងដែលមានវិការៈទី ០១ ។ ការបង់ការប្រាក់រាល់ខែរបស់ដើមចោទ គឺបង់លើប្រាក់ដើម ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ទេប្រសិនបើដើមចោទជំពាក់ ៥៩.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លាអាមេរិក) មែននោះម្លេះសម ចុងចម្លើយតវ៉ាតាំងពីដំបូងម្លេះ នេះជា

ចំណុចវិការៈទី ០២ ។ ចំណុចវិការៈទី ០៣ លិខិតខ្ចីប្រាក់ **៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក)** វាយកុំព្យូទ័រ ទុកចន្លោះប្រហោងសរសេរដៃ សម្រាប់លួចបំពេញ ទិន្នន័យបន្ថែម ។ ចំណុចមានវិការៈទី ០៤ នៅពេលកូនក្តីខ្លួន ត្អូញត្អែរអំពើការប្រាក់ ចុងចម្លើយ បានបញ្ចុះការប្រាក់ពី ៣% ក្នុង ០១ខែ មកត្រឹមតែ ២% ក្នុង០១ខែ លើប្រាក់ដើម **២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)** ។ ហើយកូនក្តីខ្លួនបានបង់ការប្រាក់សម្រាប់ខែមិថុនា កក្កដា និងខែ សីហា ឆ្នាំ ២០១៩ តែលើប្រាក់ដើមចំនួន **២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)** ចុងចម្លើយ ក៏គ្មានប្រតិកម្មអ្វីដែរ ។

- អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ បានថ្លែងតបវិញថា កូនរបស់ដើមចោទធ្លាប់បានមកខ្ចីប្រាក់ពីកូនក្តីខ្លួនជាច្រើនលើក ច្រើនដង ហើយកូនក្តីខ្លួនមានការឃោគយល់ថាជាញាតិក៏ចេះតែឲ្យខ្ចីបានធ្វើការបូកសរុបបញ្ជីហើយក៏ឲ្យសហដើមចោទផ្តិតមេដៃទទួលខុសត្រូវ ដែលមានទាំងកូនរបស់ដើមចោទក៏ផ្តិតមេដៃផងដែរ ហេតុម្តេចក៏ថាកូនក្តីខ្លួនបន្លំនេះគឺជាចេតនាទុច្ចរិតគេចវេះពីការទទួលខុសត្រូវរបស់ដើមចោទតែប៉ុណ្ណោះ ។

**<u>គ-ចំណុចមានវិវាទ និងគ្មានវិវាទ</u>**

ចំណុចមានវិវាទ ៖ រាល់ចំណុចនៃការទាមទាររបស់ដើមចោទ ចុងចម្លើយបដិសេធ គឺដើមចោទថាបានជំពាក់ប្រាក់ដើមរបស់ចុងចម្លើយចំនួន **២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)** តែចុងចម្លើយថាជំពាក់ប្រាក់ដើមខ្លួនចំនួន **៥៤.៨០០$ (ប្រាំម៉ឺនបួនពាន់ប្រាំបីរយដុល្លារអាមេរិក)** ។

## សំអាងហេតុ :

ឆ្លងតាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភ័ស្តុតាងនានា ព្រមទាំងស្តាប់ចម្លើយសាក្សី ក្នុងកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់តុលាការយល់ឃើញថា ៖

តាមការថ្លែងរបស់អ្នកតំណាងដោយអាណត្តិរបស់ភាគីដើមចោទ ខ្លួនសុំទទួលស្គាល់អ្វីដែលកូនក្តីខ្លួនបានជំពាក់ប្រាក់ភាគីចុងចម្លើយប្រាកដមែន ប៉ុន្តែគ្រាន់តែកូនក្តីខ្លួនបានសងកន្លងមកបានមួយចំនួនហើយ ត្រង់នេះការថ្លែងរបស់ភាគីដើមចោទ មានភ័ស្តុតាងគ្រប់គ្រាន់លើការថ្លែងការណ៍នេះ ។ តុលាការគប្បីទទួលស្គាល់ត្រង់ចំណុចនេះ ។ ប៉ុន្តែចំពោះការថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទលើបណ្តឹង ពុំមានភ័ស្តុតាងយកមកបញ្ជាក់លើសេចក្តីថ្លែងការណ៍របស់ខ្លួនឡើយ គប្បីតុលាការសម្រេចច្រានចោល រីឯសេចក្តីថ្លែងការណ៍តបរបស់អ្នកតំណាងដោយអាណត្តិចុងចម្លើយមានភ័ស្តុតាងគ្រប់គ្រាន់ដែលបានដាក់ជូនតុលាការពិនិត្យជាភ័ស្តុតាង ដើម្បីបញ្ជាក់លើបណ្តឹងតបរបស់ខ្លួន ។ ដូច្នេះ តុលាការគប្បីសម្រេច ទទួលស្គាល់ការទាមទារលើបណ្តឹងតបទុកជាត្រឹមត្រូវតាមច្បាប់ ។

ចំពោះការប្រាក់ និងការទាមទារលើសេវាផ្សេងៗ ការថ្លែងការណ៍របស់ភាគីអ្នកតំណាងដោយរបស់ចុងចម្លើយ បានថ្លែងការណ៍ថាទាំងការប្រាក់ និងថ្លៃសេវាផ្សេងៗខាងលើ មានមូលហេតុ និងភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់លើការទាមទារនេះ ។

ការទាមទារប្រកាសអនុវត្តជាបណ្ដោះអាសន្ន និងប្រាក់ប្រដាប់ក្ដី ដោយផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងអង្គហេតុ គប្បីតុលាការ ប្រកាសអនុវត្តជាបណ្ដោះអាសន្ន នៃចំណុចទី២ ដោយសំអាងថាអង្គហេតុដែលប្ដឹងតបរបស់អ្នកតំណាងដោយអាណត្តិចុងចម្លើយ មានភ័ស្ដុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់លើការថ្លែងការណ៍របស់ខ្លួន ដែលមានស្រាប់ក្នុងឯកសារជាភ័ស្ដុតាងដែលភាគីចុងចម្លើយ បានដាក់ជូន និងផ្អែកតាមមាត្រា ១៩៦ នៃក្រមក្រមនីតិវិធីរដ្ឋប្បវេណី នៃសេចក្ដីសម្រេច និងមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្ដីពីប្រាក់ប្រដាប់ក្ដី ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១.ច្រានចោលការទាមទាររបស់សហដើមចោទ ។

២.បង្គាប់ឱ្យភាគីសហដើមចោទសងប្រាក់ដើមចំនួន **៥៣.៨៦៣,៥០$** (ប្រាំម៉ឺនបីពាន់ប្រាំបីរយហុកសិបបីដុល្លារអាមេរិកនិងហាសិបសេន) ។

៣. បង្គាប់ឱ្យសហដើមចោទបង់ការប្រាក់ **១,៥០%** ក្នុងមួយខែតាមច្បាប់ ។

៤.បង្គាប់ឱ្យសហភាគីដើមចោទ បង់សោហ៊ុយផ្សេងៗចំនួន ៣.០០០.០០០៛ (បីលានរៀល) ការទាមទារលើសពីនេះច្រានចោល ។

៥.ប្រកាសអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី ២ នៃសេចក្ដីសម្រេច ។

៦.ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ដើមចោទ ។

**សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមច្បាប់ ។**

សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៩ និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០ ។

**ចៅក្រមជំនុំជម្រះ**

[redacted]

បានទទួលដំណឹងទុក

មេធាវី ឈ្មោះ [redacted] ឡាយ.

[redacted] ម៉ែន ឡាវ

ឡុង ដារ៉ា ឃុន .

22.04.2020.